**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
## រវាង
## រោងចក្រ វ៉ាន ហឺ ដា មេនញូហ្វេកឈើរីង ឯ.ក
## និង
## ប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានប្រចាំរោងចក្រ វ៉ាន ហឺ ដា មេនញូហ្វេកឈើរីង ឯ.ក
## ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០២០ វេលាម៉ោង ១២:០០ ថ្ងៃត្រង់នៅក្នុងរោងចក្រ វ៉ាន ហឺ ដា មេនញូហ្វេកឈើរីង ឯ.ក (Wan He Da Manufacturing Company Limited) មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងប្រតិភូបុគ្គលិក សហជីពមូលដ្ឋានប្រចាំរោងចក្រ វ៉ាន ហឺ ដា មេនញូ ហ្វេកឈើរីង ឯ.ក ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែបញ្ហាជម្ងឺកូវីដ ១៩ រីករាលដាលជាសកល បណ្តាលឲ្យក្រុមហ៊ុនខ្វះការបញ្ជាទិញ ដែលមិនអាចឲ្យសង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូលដំណើរការបាន ហេតុដូចនេះក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន **៤៦០ នាក់** រយៈពេលចំនួន **២ ខែ** គឺចាប់ពី**ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០២០** រហូតដល់**ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០២០** នៅក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះក្រុមហ៊ុន និងកម្មករនិយោជិតបានឯកភាពដូចខាងក្រោម៖

- ក្រុមហ៊ុនផ្តល់នូវប្រាក់ឧបត្ថម្ភចំនួន ៣០ ដុល្លា ក្នុង ១ ខែ សម្រាប់កម្មករនិយោជិតម្នាក់ៗ (យោងតាមសេចក្តីណែនាំលេខ ០៩៥/២០ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) ។
- ប្រាក់ឧបត្ថម្ភខាងលើនឹងបើកជូនកម្មករនិយោជិតតាមរយៈធនាគារ អេស៊ីលីដា តាមកាលវិភាគដូចការបើកប្រាក់ឈ្នួលដែលអនុវត្តជារៀងរាល់ខែ ។

អង្គប្រជុំបានចប់នៅវេលាម៉ោង ១៣:០០ រសៀល នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងខាងមានភាពស្និទ្ធស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួលខុសត្រូវ និងសហការគ្នាយ៉ាងរលូន។

ថ្ងៃ សៅរ៍ ១២ កើត ខែ ស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០២០

| **ប្រតិភូបុគ្គលិក និង តំណាងសហជីព** | | | | | | **នាយកក្រុមហ៊ុន** |
|---|---|---|---|---|---|---|
| អឹម វ៉ន | ផាន់ ទូច | ពៅ សុភ័ក្រ | សំ ជីវ៉ា | សារ៉ន ស្រស់ | បេ ណារ៉ូ | ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន វ៉ាន ហឺ ដា មេនញូហ្វេកឈើរីង ឯ.ក WAN HE DA MANUFACTURING COMPANY LIMITED KINGDOM OF CAMBODIA |
| សុខ ប៊ុនហ៊្វួន | អ៊ូង ភារ៉ា | យឹម ភារម្យ | ហ៊ាង ដែន | យឹម បូរ៉ា | ហ៊ឹម ហេង | **ប៊ុន វ៉ា** |